# អេសេគាល ១-៣ ការត្រាស់ហៅរបស់ហោរាម្នាក់

គ្រូអធិប្បាយ សាស្ត្រាចារ្យ ដន ខាសុន (Don Carson)

ជាច្រើនដងនៅក្នុងប្រវត្តិសាស្ត្រ យើងឃើញមានលាយឡំទៅដោយពេលល្អ និងពេលអាក្រក់។ នៅក្នុងប្រទេសអង់គ្លេសក្នុងអំឡុងឆ្នាំ ១៧៣៥-១៧៤០ គឺជាអំឡុងពេលមួយដ៏អាក្រក់ ដ្បិតនៅពេលនោះកើតមានបនពេស្យាចារជាច្រើន និងមានទាសករជាច្រើនផងដែរ។ អ្នកមានកាន់តែមានឡើង ឯអ្នកក្រកាន់តែក្រឡើង។ ប៉ុន្តែក៏មានពេលវេលាដ៏ល្អផងដែរ គឺនៅក្នុងឆ្នាំ ១៧៣៨ លោក George Whitefield បានអធិប្បាយដំណឹងល្អ ទៅកាន់កម្មករជីករ៉ែ ហើយពេលនោះមានមនុស្សរាប់ពាន់នាក់ បានទទួលជឿលើព្រះគ្រីស្ទ ហើយបានប្រែចិត្តពិតប្រាកដ។ នៅក្នុងឆ្នាំ១៧៤០ លោក John និងលោក Charles Wesley បានចាប់ផ្តើមអធិប្បាយដំណឹងល្អ ហើយ៧០ឆ្នាំក្រោយមក មានមនុស្សរាប់សិបនាក់នៅក្នុងប្រទេសអង់គ្លេស បានទទួលជឿលើព្រះយេស៊ូវ ដែលនោះបាននាំការផ្លាស់ប្តូរយ៉ាងធំសម្បើម ព្រមទាំងមានការអភិវឌ្ឍន៍យ៉ាងមហិមានៅក្នុងសង្គម។ ពួកអ្នកដែលបានទទួលជឿលើព្រះយេស៊ូវតាមរយៈសេចក្តីអធិប្បាយរបស់លោកវ៉ាយហ្វៀល និងលោកវ៉េស្លីបានធ្វើការផ្លាស់ប្តូរប្រទេសជាតិរបស់ពួកគេ ដូចជាបានលប់បំបាត់ទាសភាពជាដើម។ល។

មានមនុស្សជាច្រើនបាននិយាយដូចគ្នាអំពីសម័យនេះដែរ។ មានការល្អ ហើយក៏មានការអាក្រក់ផងដែរ។ យើងទទួលស្គាល់ថា សព្វថ្ងៃនេះមិនមានសង្គ្រាមទ្រង់ទ្រាយធំរវាងប្រទេសមួយ និងប្រទេសមួយកើតឡើងទេ។ មានសិស្សនិស្សិតជាច្រើន បានសិក្សានៅមហាវិទ្យាល័យ។ សម័យនេះមានអ្នកមាន ច្រើនជាងមុន។ តែទន្ទឹមគ្នានោះ ក៏មានការអាក្រក់ផងដែរ ពីព្រោះសព្វថ្ងៃនេះ មានអ្នកក្រច្រើនជាងពេលមុន មានវិវាទរវាងជាតិសាសន៍មួយ និងជាតិសាសន៍មួយ អង្គការសហប្រជាជាតិបានរកឃើញថា នៅជុំវិញពិភពលោកមានមនុស្សប្រមានជា១០០លាន់នាក់មិនមានផ្ទះសំបែង ហើយបានបោះបង់កូនចោលនៅតាមដងវិថី។

ចំនួនពេស្យាចារកុមារបានកើនឡើង៥ដងច្រើនជាងឆ្នាំ១៩៨៥។ នៅលោកខាងលិចស្ថានភាពកាន់តែអាក្រក់ឡើងៗ ខណៈពេលដែលសេចក្តីសុចរិត និងសីលធម៌បានធ្លាក់ចុះយ៉ាងគំហុក។ មានពួកជំនុំខ្លះបានចាប់អារម្មណ៍ទៅលើយុទ្ធសាស្ត្រផ្សេងៗ ជាជាងដំណឹងល្អ។ ជីវភាពគ្រួសាររស់នៅមិនចុះសំរុងគ្នា។ បណ្តាជនចាប់អារម្មណ៍យ៉ាងខ្លាំង ជាមួយនឹងជីវិតក្នុងបច្ចុប្បន្នភាពរបស់ពួកគេ តែមិនចាប់អារម្មណ៍ជាមួយនឹងជីវិតអស់កល្បជានិច្ចឡើយ សូម្បីសមាជិកនៃពួកជំនុំក៏គិតយ៉ាងនោះផងដែរ។ មានគ្រីស្ទបរិស័ទជាច្រើនយល់ថា ព្រះយេស៊ូវសំខាន់សំរាប់ពួកគេ ពីព្រោះតែអ្វីៗដែលទ្រង់អាចធ្វើសំរាប់ពួកគេ*ក្នុងពេលនេះ*។ ប៉ុន្តែអ្នកនឹងមិនអាចអានពីសេចក្តីបង្រៀនរបស់ព្រះយេស៊ូវនៅក្នុងសញ្ញាថ្មី ដោយមិនបានមើលឃើញពីវិសាលភាពដែលទ្រង់បានបញ្ជាក់យ៉ាងច្បាស់ ពីការត្រៀមខ្លួនរួចជាស្រេចសំរាប់ជីវិតអស់កល្បជានិច្ចនោះឡើយ។

យើងអាចមានការបាក់ទឹកចិត្ត នៅពេលយើងសម្លឹងមើលលោកិយនេះ ហើយគិតថា យើងបានចូលមករស់នៅក្នុងសម័យកាល ដែលគ្រប់យ៉ាងបានត្រលប់ជាអាក្រក់អស់ទៅហើយ។ តែយើងត្រូវចាំថា យើងមិនមែនជាមនុស្សដំបូង ដែលបានប្រឈមមុខជាមួយនឹងស្ថានភាពនេះនោះឡើយ។

ហោរាអេសេគាល បានរស់នៅក្នុងសម័យកាលមួយ ដែលគ្រប់យ៉ាងបានត្រលប់ជាស្មោកគ្រោក។ វាជាការមួយចាំបាច់ដែលខ្ញុំត្រូវធ្វើការពន្យល់ត្រួសៗ ពីស្ថានភាពនៅក្នុងសម័យកាលរបស់ហោរាអេសេគាល ពីព្រោះបើសិនយើងមិនយល់អំពីស្ថានភាពនៅក្នុងសម័យកាលរបស់ហោរាអេសេគាលទេ នោះយើងនឹងមិនយល់កណ្ឌអេសេគាលឡើយ។

បុត្រារបស់ស្តេចដាវីឌ បានសោយរាជ្យលើយូដាអស់ជាច្រើនសតវត្ស ប៉ុន្តែរាជ្យរបស់ពួកគេក៏បានដល់ទីបញ្ចប់។ ហោរាអេសេគាល បានរស់នៅក្នុងចុងសម័យកាលរបស់បុត្រាដាវីឌ។ ព្រះបាទយ៉ូសៀសពីឆ្នាំ ៦៤០-៦០៩ មុនគ.ស គឺជាស្តេចល្អចុងក្រោយនៃរាជវង្សរបស់ដាវីឌ។ បុត្រារបស់ទ្រង់(យ៉ូអាហាស)បានជ្រែករាជ្យ ប៉ុន្តែសោយរាជ្យបានត្រឹមតែ៣ខែ គឺរហូតដល់មហាអំណាចក្នុងតំបន់គឺអេស៊ីប បាននាំព្រះអង្គទៅប្រទេសអេស៊ីប ហើយបានតាំងយេហូយ៉ាគីមឲ្យសោយរាជ្យជំនួស (២ពង្ស. ២៣:៣៦)។ ប្រទេសអេស៊ីបបានដាក់ពន្ធដារយ៉ាងធ្ងន់ធ្ងរទៅលើប្រជាជន។ យេហូយ៉ាគីម បានពុករលួយ កើតមានចិត្តអំនួត ហើយក៏បានលើកដំកើងពួកសាសន៍ដទៃឡើង។ នៅក្នុងសង្គមនាពេលនោះ កើតមានអំពើហិង្សាគ្រប់ទិសទី។ នៅក្នុងឆ្នាំទី៤របស់ទ្រង់ គឺនៅឆ្នាំ ៦០៥មុនគ.ស ពួកអេស៊ីបបានត្រូវដួលរំលំដោយសារពួកបាប៊ីឡូន ហើយពួកនេះបានក្លាយជាចក្រភពលើលោក ហើយយូដាបានក្លាយជាជាតិសាសន៍ចំណុះរបស់បាប៊ីឡូន។ នៅឆ្នាំ ៦០១មុនគ.ស យេហូយ៉ាគីមបានបះបោរប្រឆាំងនឹងពួកបាប៊ីឡូន។ ស្តេចបាប៊ីឡូនបានបញ្ជូនកងទ័ពរបស់ខ្លួនទៅវាយប្រហារយូដា ហើយនៅក្នុងខែធ្នូ ឆ្នាំ៥៩៨មុនគ.ស ទ្រង់បានបញ្ជាឲ្យពួកកងទ័ពឡោមព័ទ្ធក្រុងយេរូសាឡិម។ ស្តេចយេហូយ៉ាគីមបានសោយជីវង្គតនៅពេលនោះតែម្តង ហើយបុត្រារបស់ទ្រង់អាយុ១៨ឆ្នាំ ព្រះនាមយ៉ូយ៉ាគីនបានឡើងសោយរាជ្យជំនួស (២ពង្ស. ២៤:៨)។ នៅក្នុងព្រះជន្ម១៨វស្សា ទ្រង់ត្រូវធ្វើការជ្រើសរើសរវាងការចុះចូល និងការបះបោរប្រឆាំង។

ទ្រង់បានស្តាប់តាមទីប្រឹក្សារបស់ទ្រង់ ដោយបានចុះចូលនៅថ្ងៃទី១៦ ខែមីនាឆ្នាំ ៥៩៧មុន គ.ស (២ពង្ស. ២៥:១២)។ ស្តេចបាប៊ីឡូនបាននាំយ៉ូយ៉ាគីន ដែលជាអ្នកដឹកនាំក្នុងក្រុងយេរូសាឡិម និងហោរាអេសេគាលទៅបាប៊ីឡូន។ ពួកគេត្រូវធ្វើដំណើរក្នុងចំងាយផ្លូវប្រមាណជា១១០០គ.ម ដើម្បីទៅដល់ស្រុកបាប៊ីឡូននោះ។ ចំងាយនេះគឺដូចគ្នានឹងចំងាយដើរពីភ្នំពេញទៅកាន់ក្រុងកំពង់សោមចំនួនប្រមាណជា៥ដង។ យ៉ូយ៉ាគីន បានជាប់ពន្ធនាគារប្រមាណជា៣៧ឆ្នាំ មុនពេលដោះលែង ហើយទ្រង់មិនបានវិលត្រឡប់មកស្រុកយូដាវិញទេ។

ពួកបាប៊ីឡូននៅតែឲ្យយ៉ូយ៉ាគីនធ្វើជាស្តេចយូដានៅឡើយ ប៉ុន្តែនៅស្រុកយូដាវិញ ព្រះបាទសេដេគាបានសោយរាជ្យបណ្តោះអាសន្នរួចទៅហើយ (២ពង្ស. ២៤:១៨)។ ហោរាអេសេគាល មិនដែលចាត់ទុកសេដេគាជាស្តេចនោះឡើយ។ សេដេគាជាស្តេចខ្សោយ ហើយពុករលួយ។ ហោរាអេសេគាលបានរស់នៅជាមួយពួកនិរទេស ខណៈពេលដែលហោរាយេរេមាបានប្រកាសបទទំនាយឲ្យពួកបណ្តាជននៅក្រុងយេរូសាឡិមស្តាប់។ ហោរាយេរេមា បានព្រមានពួកគេកុំឲ្យទាស់ប្រឆាំងជាមួយពួកបាប៊ីឡូនបន្តទៀត។ តែពួកយូដាមិនបានស្តាប់តាមនោះទេ ពួកគេបានងើបឡើងប្រឆាំងជាមួយនឹងពួកបាប៊ីឡូនទៀត។

ពួកបាប៊ីឡូនបានឆ្លើយតបចំពោះការបះបោរនោះភ្លាមៗ និងសាហាវផងដែរ។ នៅក្នុងឆ្នាំ ៥៨៨មុនគ.ស កងទ័ពបាប៊ីឡូនបានចូលមកដល់មាត់ទ្វារក្រុងយេរូសាឡិម។ នៅឆ្នាំ ៥៨៧ មុនគ.ស កងទ័ពបាប៊ីឡូនបានបំផ្លាញក្រុងយេរូសាឡិម និងព្រះវិហារផង។ ស្តេចសេដេគាបានព្យាយាមភៀសខ្លួន តែត្រូវបានពួកបាប៊ីឡូនចាប់បាន ហើយបានសំឡាប់បុត្រារបស់ទ្រង់នៅចំពោះមុខទ្រង់។ បន្ទាប់មកពួកគេបានខ្វេះភ្នែករបស់ទ្រង់ចេញ ដូច្នេះពេលចុងក្រោយដែលព្រះអង្គអាចមើលឃើញ គឺការដែលពួកបាប៊ីឡូនសំឡាប់បុត្រារបស់ទ្រង់។

ហោរាអេសេគាល បានចាប់ផ្តើមថ្លែងទំនាយនៅក្នុងឆ្នាំទី៣០ (អេសេគាល ១:១) គឺនៅពេលលោកមានអាយុ៣០ឆ្នាំ។ បន្ទាប់មកនៅក្នុងឆ្នាំទី៥នៃរាជ្យយ៉ូយ៉ាគីន (១:២) គឺនៅក្នុងឆ្នាំ ៥៩៣មុនគ.ស នៅពេលដែលពួកគេនៅក្នុងស្រុកបាប៊ីឡូននៅឡើយ ប៉ុន្តែក្រុងយេរូសាឡិមមិនទាន់ត្រូវបានបំផ្លាញនៅឡើយទេ គឺរយៈពេល៦ឆ្នាំមុនដែលក្រុងយេរូសាឡិម ត្រូវបានបំផ្លាញជាចុងក្រោយ ពេលនោះ ព្រះបន្ទូលនៃព្រះអម្ចាស់បានមកដល់អេសេគាល។

ជាការសំខាន់ ដែលត្រូវចងចាំពីភាពតានតឹងនៅក្នុងអំឡុងពេលនោះ។ គ្រប់មនុស្សដែលមានអំណោយទានល្អៗនៅក្រុងយេរូសាឡិម ពួកអ្នកដឹកនាំ ត្រូវបាននិរទេសទៅក្រុងយេរូសាឡិម។ ពេលនោះ នៅក្រុងយេរូសាឡិមមានតែស្តេចសេដេគា និងក្រុមមន្ត្រីពុករលួយដែលមានផែនការបះបោរប្រឆាំងនឹងក្រុងបាប៊ីឡូនប៉ុណ្ណោះ និងមានរយៈពេល៦ឆ្នាំបន្តទៀតមុនពេលដែលទីក្រុងត្រូវបានបំផ្លាញ។ នេះគឺជាស្ថានភាពនៅពេលចាប់ផ្តើមកណ្ឌគម្ពីរអេសេគាល។

លក្ខណៈនៃការត្រាស់ហៅរបស់ព្រះជាម្ចាស់ ចំពោះជីវិតរបស់ហោរាអេសេគាល មានសារៈសំខាន់ណាស់នៅក្នុងជំពូក ១-៣។ ប្រសិនបើយើងបានអានព្រះគម្ពីរសញ្ញាចាស់ទាំងមូលនោះយើងនឹងដឹងថា វិធីដែលព្រះជាម្ចាស់ត្រាស់ហៅមនុស្សមិនមែនតែងតែដូចគ្នាទាំងអស់នោះទេ។ ព្រះជាម្ចាស់បានត្រាស់ហៅហោរាអេសេគាលក្នុងសម័យកាលមួយ ដែលគ្រប់យ៉ាងបានត្រលប់ជាខូចអាក្រក់ ហើយ**ការត្រាស់ហៅនេះមានកត្តាសំខាន់៤យ៉ាង ដែលកត្តាទាំងនេះមានសារៈសំខាន់ណាស់សំរាប់រាស្ត្ររបស់ព្រះអង្គ នៅពេលពួកគេបានទទួលការត្រាស់ហៅឲ្យប្រកាសព្រះបន្ទូលរបស់ព្រះ**ក្នុងអំឡុងពេលដែលស្រុកទេសកើតមានភាពវឹកវរ។ ប្រសិនបើអ្នករស់នៅក្នុងវប្បធម៌ដែលគ្រប់យ៉ាងបានត្រឡប់ជាខូចអាក្រក់ នោះអ្នកត្រូវការយល់ពីការត្រាស់ហៅរបស់ព្រះចំពោះជីវិតរបស់អ្នក។ កាត្រាស់ហៅនេះមាន**កត្តា៤យ៉ាង**៖

**ទីមួយ ជាការត្រាស់ហៅឲ្យមើលឃើញព្រះអង្គ និងឲ្យចេះបន្ទាបខ្លួន (១:៤-២:២)។**

១:៤ ចាប់ផ្តើមឡើងដោយមានព្យុះធូលី។ វាអាចជានិមិត្តមួយ ឬអាចជាព្យុះធូលីពិតមែន។ និមិត្តមានទីសំគាល់ច្រើនយ៉ាង។ ឧទាហរណ៍ និមិត្តឃើញកង់មានភ្នែក។ តាមធម្មតាយើងមិនដែលធ្វើកង់មានភ្នែកនោះទេ។ និមិត្តឃើញដំពពកយ៉ាងធំ (ខ៤) ហើយឃើញមាននៅចំកណ្តាលភ្លើង មានដំលោហៈភ្លឺ ហើយមានតួមានជីវិត៤នៅក្នុងភ្លើងនោះ។ នេះគឺជារូបភាពនៃបល្ល័ង្កចល័តរបស់ព្រះជាម្ចាស់។

ពួកយូដាភាគច្រើននៅសម័យនោះយល់ថា ព្រះជាម្ចាស់បានគង់នៅក្នុងក្រុងយេរូសាឡិម ប៉ុន្តែនៅត្រង់នេះយើងបានឃើញថា ព្រះជាម្ចាស់បានបើកសំដែងអង្គទ្រង់ឲ្យពួកសំណល់នៅស្រុកបាប៊ីឡូនបានឃើញ ទ្រង់គង់នៅលើបល្ល័ង្កចល័តនេះវិញ។

តួមានជីវិតទាំង៤ មានស្លាប៤និងមុខ៤(១:៦)។ មុខទាំង៤នោះគឺមុខជាមនុស្ស ជាសឹង្ហ ជាគោ និងជាឥន្ទ្រី(១:១០)។ និមិត្តសញ្ញាទាំងនេះបានបង្ហាញយ៉ាងច្បាស់ ហើយវាក៏បានលេចឡើងម្តងទៀតនៅក្នុងកណ្ឌវិវរណៈ។ បល្ល័ង្ករបស់ព្រះជាម្ចាស់មានពេញដោយប្រាជ្ញា (មុខជាមនុស្ស) ជាស្តេច (មុខសឹង្ហ) ប្រកបដោយកំលាំង (មុខជាសត្វគោ) ហើយនិងមុខជាសត្វឥន្ទ្រី ប្រហែលជានិមិត្តរូបនៃក្តីមេត្តាករុណា ឬការថែទាំ ពីព្រោះមានសត្វឥន្ទ្រីខ្លះមានវិធីសាស្ត្ររបស់ខ្លួនក្នុងការបង្ហាត់បង្រៀនដល់កូនក្នុងការហោះហើរ ដែលជាភស្តុតាងមួយបង្ហាញពីការថែរក្សាដ៏អស្ចារ្យ។

នៅពេលនោះមានផ្សូងថ្មឆេះឡើង មានផ្លេកបន្ទោរ និងរន្ទះ (ខ១៣) ដែលនៅក្នុងសញ្ញាចាស់ គឺជានិមិត្តសញ្ញានៃវត្តមានដ៏គួរឲ្យភ័យខ្លាចរបស់ព្រះជាម្ចាស់។ មុនពេលសម័យបច្ចេកៈវិទ្យាដ៏ទំនើបនេះ អំណាចដ៏ខ្លាំងបំផុតនោះគឺព្យុះរន្ទះនេះឯង។ ដូច្នេះ នៅលើភ្នំស៊ីណាយ យើងឃើញមានសំលេងផ្គរ និងរន្ទះ ឯបល្ល័ង្ករបស់ព្រះជាម្ចាស់នៅត្រង់នេះ មានពេញដោយពន្លឺនៃរន្ទះ។

តួមានជីវិតទាំងនោះ មិនមែនចេះតែធ្វើចលនាតាមចិត្តនោះទេ។ បល្ល័ង្ករបស់ព្រះជាម្ចាស់ធ្វើការតាមទិសដៅរបស់ព្រះជាម្ចាស់នៅពេលទ្រង់បញ្ជា។ តួមានជីវិតទាំងនោះបានសន្ទឹងស្លាបរបស់ខ្លួន ធ្វើឲ្យចុងស្លាបទាំងសងខាងប៉ះគ្នា (ខ១១)

ហើយបង្កើតបានជាប្រហោងបួនជ្រុងដែលនោះគឺជាកន្លែងសំរាប់បល្ល័ង្កនេះឯង។ តួមានជីវិតមួយៗមានក្បាល៤ ហើយគ្រប់ទាំងអស់បានធ្វើការជាមួយគ្នានៅពេលព្រះវិញ្ញាណធ្វើចលនា។

ខ១៥ បានបង្រៀនថា នៅខាងចំហៀងនៃតួមានជីវិតនីមួយៗមានកង់មិនធម្មតាមួយ ដែលមានពេញដោយភ្នែក (ខ១៨) ដែលនោះគឺជានិមិត្តសញ្ញានៃសព្វញ្ញូភាព។ បល្ល័ង្ករបស់ព្រះជាម្ចាស់ទតឃើញគ្រប់យ៉ាងទាំងអស់ មានន័យថា ព្រះជាម្ចាស់ទតឃើញគ្រប់ទាំងអស់។

ដូច្នេះបល្ល័ង្ករបស់ព្រះជាម្ចាស់គឺជាប្រាជ្ញា ស្តេច កំលាំង ការមើលថែរនិងការមើលឃើញគ្រប់អ្វីៗទាំងអស់។

បន្ទាប់មកខ២២ បានថែងថា នៅពីលើក្បាលរបស់ពួកគេមានពន្លឺចាំងផ្លេតៗដូចជាទឹកកក(*ដូចជាផ្ទៃមេឃ ដែល មើលទៅដូចជាចរណៃគួរស្ញែងខ្លាច*) ហើយនៅពីក្រោមវានៅពេលតួមានជីវិតទាំងនោះផ្លាស់ទីនោះសម្លេងស្លាបរបស់វាឮសូរដូចសំលេងទឹកហូរ *ដូចជាព្រះសូរសៀងនៃព្រះដ៏មានគ្រប់ព្រះចេស្តា* (ខ២៤) គឺសម្លេងដូចជាសូរសន្ធឹកកងទ័ព។ ប្រសិនបើអ្នកឈរជិតទឹកជ្រោះ នោះសំលេងទឹកនឹងលាន់ឮយ៉ាងខ្លាំង រហូតធ្វើឲ្យអ្នកមិនអាចស្តាប់ឮអ្វីទាល់តែសោះ។

ដូច្នេះនៅពេលបល្ល័ង្ករបស់ព្រះជាម្ចាស់ធ្វើចលនា គឺដូចជាសម្លេងដែលព្រះជាម្ចាស់ធ្វើចលនាដែរ វាមានសម្លេងលាន់ឮយ៉ាងខ្លាំង គឺដូចជាសម្លេងអឺងកងនៃកងទ័ព ឬសម្លេងទឹកធ្លាក់គំហុកយ៉ាងនោះដែរ។

នេះគ្រាន់តែជាការរៀបចំ សំរាប់អ្វីដែលនឹងត្រូវមកដល់ប៉ុណ្ណោះ។ មានលំហដ៏ធំនៅពីលើក្បាលរបស់ពួកគេ ហើយនៅពីលើលំហរនោះ គឺមានអ្វីមួយដែលមើលទៅដូចជាបល្ល័ង្កនៃត្បូងកណ្តៀង ហើយនៅពីលើបល្ល័ង្កនោះ ឃើញមានរូបមួយរាងដូចជាមនុស្ស (ខ២៦)។ តែនៅពេលអ្នកកាន់តែខិតចូលជិតរូបនេះ នោះអ្នកកាន់តែមើលឃើញនិមិត្ត ត្រូវបានពន្យល់ដោយការឧបមា។ នេះគឺ «ដូចជាមនុស្ស» (ខ២៦) «អ្វីដែលបានលេចឡើងគឺជា» (ខ២៧) «មើលទៅដូចជា» (ខ២៧) «ដូចភ្លើង» (ខ២៧) «មានរាងដូចឥន្ទធនូ (ខ២៨)។




បន្ទាប់មកព្រះគម្ពីរបានថែងថា «នេះជាគំរូពីភាពនៃសិរីល្អរបស់ព្រះយេហូវ៉ា» (ខ២៨)។

អ្នកមិនអាចគូសរូបភាព ពីសិរីល្អរបស់ព្រះជាម្ចាស់បានឡើយ។ ហោរាអេសេគាល បានត្រឹមតែប្រើពាក្យប្រៀបធៀបតែប៉ុណ្ណោះ។ យើងមិនអាចគូសរូបភាពពីព្រះជាម្ចាស់ ដោយសំអាងលើនិមិត្តឡើយ។ ព្រះជាម្ចាស់មានភាពអស្ចារ្យជាងអ្វីដែលយើងអាចគូស។ យើងមិនអាចគូសរូបភាពហើយនិយាយថា «នេះគឺជាព្រះរបស់ខ្ញុំ» បន្ទាប់មកក៏លុតជង្គង់ហើយថ្វាយបង្គំនោះឡើយ។

បន្ទាប់មកហោរាអេសេគាលបានមានប្រសាសន៍ថា «*កាលខ្ញុំបានឃើញហើយនោះខ្ញុំក្រាបមុខចុះ ដល់ដី ហើយខ្ញុំឮព្រះសូរសៀងមានបន្ទូលមក។ ទ្រង់មានបន្ទូលមកខ្ញុំថា កូនមនុស្សអើយ ចូរក្រោកឈរឡើង នោះ អញនឹងនិយាយនឹងឯង*» (១:២៨ខ-២:១)។

កត្តាដំបូងនៃការត្រាស់ហៅរបស់ហោរាអេសេគាលគឺ លោកបានឃើញព្រះ និងបន្ទាបខ្លួន។ វាជាការសំខាន់ណាស់ក្នុងការមើលឃើញព្រះអង្គ ប៉ុន្តែនៅក្នុងវប្បធម៌មួយ ដែលមិនមានការពេញនិយមក្នុងការនិយាយពីការស្គាល់ព្រះ និងទទួលយកព្រះដ៏អស្ចារ្យនេះ នោះវាកាន់តែមានសារៈសំខាន់ថែមទៀតក្នុងការមើលឃើញសិរីរុងរឿងរបស់ព្រះអង្គ និងបានបន្ទាបខ្លួនចុះដោយសារព្រះអង្គ។ ប្រសិនបើអ្នកមិនបានមើលឃើញនោះទេ នោះអ្នកនឹងមិនអាចមានកំលាំងបានឡើយ។

ដូច្នេះ គ្រប់ទាំងនិមិត្តរបស់ព្រះជាម្ចាស់ដែលអ្នកបានមើលឃើញ តាមរយៈព្រះគម្ពីរម្តងហើយម្តងទៀត ត្រូវបានប្រទានទៅឲ្យពួកអ្នកដែលត្រូវការកំលាំង ក្នុងអំឡុងពេលគ្រោះថ្នាក់ ឬអាក្រក់។ ហោរាអេសាយ បានរស់នៅក្នុងអំឡុងពេលដ៏អាក្រក់ ហើយលោកក៏បានទទួលនិមិត្តដ៏អស្ចារ្យពីព្រះជាម្ចាស់ដែរ។ សាវកយ៉ូហាន ជាអ្នកថ្លែងបទទំនាយនៅក្នុងកណ្ឌវិវរណៈជំពូក១ បានមើលឃើញនិមិត្តដ៏អស្ចារ្យមួយពីព្រះជាម្ចាស់ ខណៈពេលដែលពួកជំនុំកំពុងតែប្រឈមមុខជាមួយនឹងការគំរាមកំហែងដ៏ធ្ងន់ធ្ងរ។

**ទីពីរ វាជាត្រាស់ហៅឲ្យថ្លែងព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដោយគ្មានការភ័យខ្លាច (២:៣-៨)។**

ព្រះជាម្ចាស់បានមានបន្ទូលទៅកាន់ហោរាអេសេគាល *«កូនមនុស្សអើយ អញចាត់ឯងឲ្យទៅឯពួកកូនចៅអ៊ីស្រាអែល គឺដល់សាសន៍ដែលរឹងចចេស ដែលបានបះបោរនឹងអញ»* (ខ៣)។ និយាយម្យ៉ាងទៀត ការទាស់ប្រឆាំងធំបំផុតមិនមែនជាការប្រឆាំងទាស់និងពួកបាប៊ីឡូននោះទេ តែប្រឆាំងទាស់នឹងព្រះជាម្ចាស់វិញ។

ពួកហោរារបស់ព្រះជាម្ចាស់បានប្រាប់ពួកគេពីអ្វីដែលត្រូវធ្វើ តែពួកបណ្តាជនមិនបានយកចិត្តទុកដាក់ស្តាប់នោះទេ ជាតិសាសន៍នេះទាំងមូល និងពូជពង្សរបស់ដាវីឌទាំងអស់ផងដែរ បានធ្លាក់ដោយព្រោះការបះបោរប្រឆាំងទាស់នឹងព្រះជាម្ចាស់របស់ពួកគេ។ ព្រះជាម្ចាស់បានបន្តមានបន្ទូលទៅកាន់ហោរាអេសេគាលថា *ទោះទាំងខ្លួនគេនិងពួកឰយុកោ ក៏បានរំលង ទាស់នឹងអញ ដរាបដល់ថ្ងៃនេះឯងគេជាកូនចៅមានមុខរឹង ហើយចិត្ត ខែង គឺដល់ពួកអ្នកនោះដែលអញចាត់ឯង ត្រូវឲ្យឯងប្រាប់គេថា ព្រះអម្ចាស់យេហូវ៉ា ទ្រង់មានបន្ទូលដូច្នេះ ឯគេ ទោះបើគេនឹងព្រម ស្តាប់ ឬមិនព្រមក្តី (ដ្បិតគេជាពូជពង្ស រឹងចចេស) គង់តែគេនឹងដឹងថា មានហោរា១ បានមកក្នុងពួកគេហើយ* (២:៣ខ-៥)។

ព្រះជាម្ចាស់ជ្រាបពីអ្វីដែលហោរាអេសេគាលកំពុងគិត ហេតុនេះទើបទ្រង់បានមានបន្ទូលទៅលោកនៅក្នុងខ៦ថា *ឯឯង កូនមនុស្សអើយ កុំឲ្យ ខ្លាចគេឡើយ ក៏កុំឲ្យខ្លាចចំពោះពាក្យសំដីរបស់គេដែរ ទោះបើមាន បន្លា ហើយនឹងអញ្ចាញមកទាស់ជាមួយនឹងឯង ហើយឯងមានទីអាស្រ័យ នៅកណ្តាលពួកខ្យាដំរីក៏ដោយ កុំឲ្យខ្លាចពាក្យសំដីគេឲ្យសោះក៏ កុំឲ្យស្លុតចិត្តនឹងទឹកមុខគេដែរ ទោះបើគេជាពូជពង្សរឹងចចេសក៏ ដោយត្រូវឲ្យឯងថ្លែងពាក្យរបស់អញប្រាប់ដល់គេ ទោះបើគេនឹង ព្រមស្តាប់ ឬមិនព្រម ក្តី ដ្បិតគេរឹងចចេសណាស់*។

ចូរកត់សំគាល់ នៅត្រង់ការទទួលយកនិងប្រកាសព្រះបន្ទូលព្រះដ៏ត្រឹមត្រូវ។ ត្រូវចាំថា វាជាការសំខាន់ណាស់ដែលថាអស់ពួកអ្នកដែលធ្វើបន្ទាល់ពីព្រះជាម្ចាស់ នឹងនិយាយព្រះបន្ទូលរបស់ព្រះ។ នេះគឺជាហេតុផលមួយដែលព្រះជាម្ចាស់បានប្រទានព្រះគម្ពីរមក។ វាអាចនឹងជួបការលំបាកក្នុងការនិយាយព្រះបន្ទូលរបស់ព្រះជាម្ចាស់ទៅកាន់ពួកអ្នកដែលមិនចង់ឮ។ ខ្ញុំបានធំពេញវ័យនៅក្នុងផ្នែកមួយនៃប្រទេសកាណាដាដែលនិយាយភាសាបារាំង នៅចន្លោះឆ្នាំ ១៩៥០-១៩៥២ ពេលនោះពួកគ្រូគង្វាលបាទីស្ទខ្លះ នៅក្នុងប្រទេសកាណាដាត្រូវបានជាប់ពន្ធនាគារ ដោយព្រោះអធិប្បាយដំណឹងល្អ។ មានពួកអ្នកជឿលើដំណឹងល្អខ្លះ បានបាត់បង់មុខជំនួញរបស់ពួកគេ ហើយផ្ទះសំបែងរបស់ពួកគេត្រូវបានបំផ្លាញ។ ពេលនោះគឺជាអំឡុងពេលដ៏គ្រោះថ្នាក់មួយ។ វាជាអំឡុងពេលដ៏គ្រោះថ្នាក់មួយនៅក្នុងជំនួបលើកដំបូងរបស់វ៉ាយហៀល និងវេស្លីនៅក្នុងប្រទេសអង់គ្លេសដែរ។ ប៉ុន្តែខណៈពេលដែលពួកជំនុំរីកដុះដាលច្រើនឡើង នោះពួកអធិប្បាយព្រះបន្ទូលត្រូវបានទទួលការគោរព។ វាជាកិត្តិយសមួយក្នុងការធ្វើជាអ្នកបំរើព្រះជាម្ចាស់។ មិនមែនថារាល់ពេលពួកគេបានទទួលការស្រឡាញ់ ចូលចិត្តនោះទេ ប៉ុន្តែពួកគេបានទទួលការគោរព។ តែនៅពេលលេចឡើងនូវវប្បធម៌ទាស់ប្រឆាំងនឹងដំណឹងល្អ នោះងាយ

ណាស់ក្នុងការទទួលការភ័យខ្លាច។ គឺភ័យខ្លាចចំពោះការយល់ឃើញរបស់ពួកបណ្ដាជន។ ហោរាអេសេគាលបានយល់ពីការទាំងអស់នេះ ពីព្រោះលោកមានសារមួយដែលមិនមានការនិយមពេញចិត្តសោះ ហើយព្រះជាម្ចាស់បានត្រាស់បង្គាប់លោក ឲ្យប្រកាសព្រះបន្ទូលរបស់ទ្រង់ ដោយមិនត្រូវមានការភ័យខ្លាចឬទាស់ប្រឆាំងឡើយ។

ចូរកត់សំគាល់ថា ព្រះជាម្ចាស់មិនបានសន្យាថា នឹងមានការភ្ញាក់ឡើងវិញនោះទេ។ ហោរាអេសេគាលត្រូវតែប្រកាសព្រះបន្ទូលរបស់ព្រះជាម្ចាស់ ទោះបីពួកបណ្ដាជនស្ដាប់ឬមិនស្ដាប់ក្ដី។

ត្រូវចាំថា វាជាការសំខាន់បំផុតដែលត្រូវប្រកាសព្រះបន្ទូលរបស់ព្រះជាម្ចាស់ ជាពិសេសនៅពេលយើងរស់នៅក្នុងអំឡុងពេលដែលអាក្រក់ ឬក្នុងអំឡុងពេលដែលគ្រប់យ៉ាងបានត្រឡប់ជាពុករលួយ ពីព្រោះយើងត្រូវការការលើកទឹកចិត្តខ្លាំង និងព្រះបន្ទូលព្រះគឺជាវិធីតែមួយគត់ដែលអាចផ្លាស់ប្ដូរមនុស្សបាន។

មិនថាព្រះបន្ទូលព្រះប្រកាសពីការវិនិច្ឆ័យឬ តាមរយៈព្រះបន្ទូលនោះ ទ្រង់បាននាំការផ្លាស់ប្រែយ៉ាងណានោះទេ គ្រប់យ៉ាងគឺសុទ្ធតែព្រះអង្គជាអ្នកធ្វើការតាមរយៈព្រះបន្ទូលរបស់ទ្រង់ទាំងអស់។

តើអ្នកណាដឹងថា ព្រះអង្គនឹងធ្វើការអ្វីនៅក្នុងប្រទេសនេះឬទេ? ខ្ញុំមិនដឹងទេ។ ព្រះអង្គអាចនឹងលើកពួកអ្នកអធិប្បាយល្បីៗឡើង ពីក្នុងចំណោមពួកអ្នកដែលស្ដាប់ព្រះបន្ទូលនេះ ដែលនឹងនាំមនុស្សជាច្រើនទៅឯព្រះគ្រីស្ទ។

ខ្ញុំដឹងជាប្រាកដថា ការនេះនឹងមិនកើតឡើងតាមរយៈពួកអ្នកដែលបានផ្លាស់ប្ដូរ ព្រះបន្ទូលរបស់ព្រះនោះទេ។ តែវានឹងកើតឡើងតាមរយៈពួកអ្នកដែលចង់ក្លាយខ្លួនជាអ្នកស្មោះត្រង់ ចំពោះព្រះបន្ទូលរបស់ព្រះអង្គវិញ។

ចេញពីទស្សនៈរបស់ព្រះជាម្ចាស់ មានវិធីតែមួយគត់ដែលអ្នកអាចបរាជ័យ គឺការដែលអ្នកបិទមាត់ មិនប្រកាសព្រះបន្ទូល។ ភាពជោគជ័យ ឬបរាជ័យរបស់អ្នកមិនមែនវាស់វែងតាមរយៈបរិមាណរបស់មនុស្សដែលប្រែចិត្តជឿ ឬមិនប្រែចិត្តជឿនោះទេ។ ការបរាជ័យរបស់អ្នកត្រូវបានវាស់វែងតាមរយៈអ្វីដែលព្រះជាម្ចាស់ហៅថា បះបោរ និងការដែលអ្នក មិនបានប្រកាសព្រះបន្ទូលរបស់ព្រះជាម្ចាស់។ នេះជាការមួយសំខាន់ដែលត្រូវចងចាំ ពីព្រោះវប្បធម៌របស់យើងមានការយល់ដឹងបន្តិចបន្តួចប៉ុណ្ណោះអំពី ព្រះបន្ទូលរបស់ព្រះជាម្ចាស់។ វាត្រូវការចំណាយពេលយ៉ាងច្រើនដើម្បីបង្រៀនគ្រប់ទាំងព្រះបន្ទូលរបស់ព្រះ ដើម្បីផ្លាស់ប្ដូរទស្សនវិស័យលោករបស់ពួកគេ។

ខ្ញុំមិនមែនមានគំនិតទិដ្ឋិនិយមជាមួយវប្បធម៌របស់ខ្លួនឯងនោះទេ សូម្បីតែវាបានត្រលប់ជាខូចអាក្រក់យ៉ាងណាក្ដី ដ្បិតព្រះនៅតែអាចផ្លាស់ប្ដូរគ្រប់ទាំងស្ថានភាពបាន។ ខ្ញុំមិនដាក់សេចក្ដីសង្ឃឹមរបស់ខ្ញុំទៅលើការល្អរបស់មនុស្សនោះទេ ប៉ុន្តែទុកចិត្តលើសមត្ថភាពរបស់ព្រះ ជាម្ចាស់ក្នុងការផ្លាស់ប្ដូរយើងវិញ។

**ទី៣ វាជាការត្រាស់ហៅឲ្យស្គាល់ពីទិដ្ឋិភាពរបស់ព្រះជាម្ចាស់និងដើរតាមគ្រប់ទាំងមាគ៌ារបស់ទ្រង់ (២:៩-៣:១៥)។**

ប្រសិនបើជំពូក២ ជាជំពូកនិទានអំពីការតែងតាំងរបស់ហោរាអេសេគាល នោះជំពូកនេះនឹងបំពាក់បំប៉នហោរាអេសេគាល។ មានក្រាំងមួយដែលបានសរសេរចុះទាំងសងខាង។ ក្រាំងភាគច្រើននៅក្នុងលោកនេះនាបុរាណសម័យ ត្រូវបានគេសរសេរតែលើផ្នែកម្ខាងប៉ុណ្ណោះ ប៉ុន្តែអ្នកអាចសរសេរលើផ្នែកទាំងសងខាង ប្រសិនបើអ្នកចង់សរសេរចុះនូវអ្វីៗដែលអ្នកមាននៅក្នុងកន្លែងតែមួយ។ ដូច្នេះនេះគឺជានិមិត្តសញ្ញាបញ្ជាក់ថា ក្រាំងនេះមាន*គ្រប់*ទាំងការវិនិច្ឆ័យរបស់ព្រះជាម្ចាស់ ការទួញយំ ទុក្ខសោក ហើយព្រះអង្គបានបង្គាប់ឲ្យហោរាអេសេគាលបរិភោគក្រាំងនោះ (៣:១)។ បន្ទាប់មកហោរាអេសេគាលបានមានប្រសាសន៍ថា *នោះខ្ញុំ ក៏បរិភោគទៅ ឯនៅក្នុងមាត់ខ្ញុំ ក្រាំងនោះមានរសជាតិផ្អែមដូចជាទឹកឃ្មុំ* (ខ៣)។

នេះគួរឲ្យភ្ញាក់ផ្អើលខ្លាំងណាស់។ ក្រាំងទាំងអស់សុទ្ធតែចែងពីការវិនិច្ឆ័យ ការទួញយំ ការយំសោក និងហោរាអេសេគាលយល់ថាទាំងអស់នោះមានរស់ជាតិផ្អែម។ តើនៅត្រង់នេះចង់និយាយពីអ្វី? នៅត្រង់នេះចង់បង្ហាញថាទស្សនៈរបស់ហោរាអេសេគាល ពេលនេះស្របតាមទស្សនៈរបស់ព្រះជាម្ចាស់ ចិត្តគំនិតរបស់លោកនៅជាប់ជាមួយព្រះជាម្ចាស់ ហេតុនេះទោះបីជាទ្រង់ប្រកាសពីការវិនិច្ឆ័យ និងការយំសោកយ៉ាងណាក៏ដោយ ហើយទោះបីមានការឈឺចាប់យ៉ាងណាក្តី (អេសេគាលនឹងតវ៉ានៅពេលក្រោយ) ក៏លោកបានឆ្លើយតបទៅព្រះអង្គចេញពីចិត្តថា «មែនហើយ» ផ្លូវនិងព្រះបន្ទូលរបស់ព្រះជាម្ចាស់ត្រឹមត្រូវមែន។

ពិបាកណាស់ ក្នុងការប្រកាសពីព្រះបន្ទូលវិនិច្ឆ័យរបស់ព្រះជាម្ចាស់ ប្រសិនបើអ្នកចង់ឲ្យព្រះជាម្ចាស់ចេញឲ្យឆ្ងាយ ឬអ្នកគិតថាព្រះជាម្ចាស់ដូចជាមិនយុត្តិធម៌សោះនោះ។ ប៉ុន្តែប្រសិនបើអ្នកមើលឃើញពីភាពបរិសុទ្ធរបស់ព្រះជាម្ចាស់ នោះទោះបីជាទ្រង់ប្រកាសពីការវិនិច្ឆ័យ និងយំសោកក្តី ក៏អ្នកនៅមានអំណរតាមរបៀបមួយដែរ ទោះបីជារបៀបផ្សេងទៀតអ្នកមិនមានអំណរក៏ដោយ។

នៅក្នុង៣:៧ ព្រះជាម្ចាស់បានព្រមានហោរាអេសេគាលថា ពួកអ៊ីស្រាអែលនឹងមិនស្តាប់លោកឡើយ ពីព្រោះពួកគេមិនព្រមស្តាប់តាមព្រះអង្គ តែនៅក្នុង៣:៨-៩ ព្រះជាម្ចាស់បានមានបន្ទូលថា *មើលអញធ្វើ ឲ្យមុខឯងបានរឹងតនឹងមុខគេ ហើយក្បាលឯងបានរងឹតនឹងក្បាលគេ ដែរអញបានធ្វើឲ្យក្បាលឯងរឹង ដូចជាពេជ្រដែលរឹងជាងថ្មដែក និងភ្លើងទៅទៀត កុំឲ្យខ្លាចគេឡើយ ក៏កុំឲ្យស្លុតនឹងទឹកមុខរបស់គេដែរ ទោះបើគេជាពូជពង្សរឹងចចេសក៏ដោយ*

ដូចដែលព្រះជាម្ចាស់បានមានបន្ទូលដែរថា ទ្រង់នឹងដាក់ហោរាអេសេគាលឲ្យប្រកួតប្រជែងជាមួយនឹងពួកអ៊ីស្រាអែលជាកន្លែងដែលពួកគេទង្គិចក្បាលគ្នាទៅវិញទៅមក ហើយព្រះជាម្ចាស់នឹងបំពាក់បំប៉នហោរាអេសេគាលដោយប្រទានដល់លោកនូវថ្វាសដែលរឹងជាងពួកអ៊ីស្រាអែល។

ប្រសិនបើអ្នកក្រឡេកមើលប្រវត្តិសាស្ត្រឡើងវិញ គឺទាំងប្រវត្តិសាស្ត្រព្រះគម្ពីរ និងប្រវត្តិសាស្ត្រពួកជំនុំ នោះអ្នកនឹងដឹងថា មានពេលដែលមនុស្សជាច្រើនបានវិលបែរមកឯព្រះ ក្នុងនោះមានពួកអ្នកដឹកនាំ (ពួកនោះអាចជាមនុស្សសុភាពរៀបសារ) ដែលសុទ្ធតែមានកំលាំងខ្លាំងក្លា ហើយពួកគេមិនដើរតាមពួកបណ្តាជនឬផ្គាប់ចិត្តដល់ពួកបណ្តាជនឡើយ។ ចូរប្រយ័ត្នកុំឲ្យយល់ច្រលំពីការបំរើមនុស្ស និងការដើរតាមមនុស្ស។

ពួកអ្នកដឹកនាំល្អៗទាំងនេះ នឹងមិនស្តាប់តាមសំលេងរបស់ពួកបណ្តាជន ដែលមានចិត្តគំនិតមិនដើរតាមព្រះ បន្ទូលរបស់ព្រះជាម្ចាស់ ប៉ុន្តែពួកគេនឹងប្រកាន់ភ្ជាប់ក្នុងការដើរតាមផ្លូវល្អ ដើរតាមព្រះបន្ទូលព្រះ និងប្រកាសព្រះបន្ទូលរបស់ទ្រង់ទោះបីជាការនេះធ្វើឲ្យពួកគេបាត់បង់ប្រជាប្រិយភាពក៏ដោយ។ ពួកគេមិនទោទន់ទៅរកពួកបណ្តាជនឡើយ។ ពួកគេត្រូវតែមានលក្ខណៈសម្បត្តិយ៉ាងនេះ ដើម្បីអោយមានក្តីសង្ឃឹមថាព្រះជាម្ចាស់នឹងផ្លាស់ប្តូរស្ថានភាព។

ពួកគេមិនទោទន់ទៅខាងបណ្តាជនឡើយ។ នេះមិនមែនបានសេចក្តីថាពួកគេមានអំនួត ឬមិនមានចិត្តមេត្តាធម៌នោះទេ ប៉ុន្តែដោយព្រោះព្រះជាម្ចាស់បានប្រទានសមត្ថភាពដល់ពួកគេឲ្យស្មោះត្រង់ជាមួយនឹង ព្រះបន្ទូលរបស់ទ្រង់។

បន្ទាប់មកនៅក្នុង ៣:១២ បានចែងថា *លំដាប់នោះព្រះវិញ្ញាណទ្រង់លើកខ្ញុំឡើង ហើយខ្ញុំឮសូរ អឺងអាប់ ជាខ្លាំងពីក្រោយខ្ញុំថា សូមឲ្យសិរីល្អនៃព្រះយេហូវ៉ាបានពរពី ស្ថាន របស់ទ្រង់មក ហើយក៏ឮសូរសន្ធឹកនៃស្លាបរបស់តួមានជីវិតទាំងនោះ ដែលប៉ះ គ្នា នឹងសូររបស់កង់ទាំងនោះដែលអមទៅ គឺជាសូរអឺងអាប់ យ៉ាងខ្លាំងដូច្នេះព្រះវិញ្ញាណទ្រង់លើកខ្ញុំឡើងយកទៅ ឯខ្ញុំក៏ទៅដោយ មានសេចក្តីជូរចត់ ហើយដោយសេចក្តីក្តៅក្រហាយនៃវិញ្ញាណខ្ញុំ ព្រះហស្តនៃព្រះយេហូវ៉ាក៏សណ្ឋិតលើខ្ញុំជាខ្លាំងដែរ*

ចិត្តគំនិតរបស់ហោរាអេសេគាល នៅពេលនេះបានដើរតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ ដូច្នេះហើយនៅពេលលោកដឹងពីអំពើបាបរបស់ពួកអ៊ីស្រាអែល លោកក៏មានចិត្តខឹងចំពោះអំពើបាបទាំងនោះដែរ។

បន្ទាប់ពីមានបទពិសោធន៍នេះហើយ លោកបានអង្គុយនៅមាត់ស្ទឹងជាមួយនឹងអ្នកមានវ័យស្រេករលោក (៖១៥) ក្នុងស្រុកបាប៊ីឡូន។

មានលេចឡើងនូវសិរីល្អខ្លះៗទាក់ទងនឹងការនេះ ពួកអ្នកដឹកនាំបានមើលឃើញសិរីល្អរបស់ព្រះជាម្ចាស់ ហេតុនេះពួកគេនៅជាប់ជាមួយនឹងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ទោះបីពេលនោះមានការខឹងសម្បារ តែក្នុងពេលជាមួយគ្នានោះ អ្នកត្រូវមានចិត្តអាណិតអាសូរចំពោះពួកអ្នកដែលអ្នកបំរើដែរ។

អ្នកអាចមានគ្រូអធិប្បាយ ដែលមានទស្សនៈរបស់ព្រះជាម្ចាស់ តែពួកគេតែងមានចិត្តខឹងសម្បាគ្រប់ពេល ជាមនុស្សកាច អាក្រក់។ តែផ្ទុយទៅវិញ មានមនុស្សកំសាកដែលចង់តែផ្គាប់ចិត្តមនុស្ស ដូច្នេះពួកគេតែងនិយាយពីអ្វីដែលមនុស្សចង់ស្តាប់ និយាយពីអ្វីដែលមានការទាក់ទាញ។ ហោរាអេសេគាល មិនមែនជាមនុស្សបែបនោះនោះទេ។ លោកខឹងសម្បាចំពោះគ្រប់ទាំងអំពើបាប តែជាមួយគ្នាលោកអង្គុយជាមួយនឹងជនរួមជាតិដ៏ច្រើនលើសលប់របស់លោកហើយលោកមានការស្រឡាញគាំងយ៉ាងខ្លាំង។

**ទី៤ ការត្រាស់ហៅគឺដើម្បីប្រកាសពីសេចក្តីព្រមានផ្សេងៗ និងត្រូវប្រុងប្រយ័ត្ន (៣:១៦-២៧)។**

ព្រះជាម្ចាស់បានអនុញ្ញាតឲ្យហោរាអេសេគាលនិយាយពីអ្វីដែលទ្រង់ចង់ឲ្យគាត់និយាយប៉ុណ្ណោះ (៣:២៦-២៧)។ លោកមិនអាចនិយាយអ្វីផ្សេងបានឡើយ សូម្បីពាក្យបដិសណ្ឋារកិច្ច ដូចជាសួស្តី ឬជំរាបលាក៏មិនបានផង។ នេះកើតឡើងអស់រយៈពេល៦ឆ្នាំ។ ព្រះគម្ពីរបានប្រាប់យើងថា ហោរាអេសេគាលអាចនិយាយម្តងទៀតនៅក្នុងអេសេ. ៣៣ គឺនៅពេលលោកបានឮថាក្រុងយេរូសាឡិមបានដួលរំលំ។

តើអ្នកអាចស្រមៃមើលឃើញពីឥទ្ធិពលនេះឬទេ? លោកមិនអាចនិយាយអ្វីផ្សេងសូម្បីមួយម៉ាត់ អស់រយៈពេលរាប់ខែបន្ទាប់មកស្រាប់តែអាចនិយាយថា «នេះជាព្រះបន្ទូលរបស់ព្រះយេហូវ៉ា»។ ពេលនោះពាក្យប្រកបដោយអំណាចពីព្រោះមានតែពាក្យនោះប៉ុណ្ណោះដែលលោកអាចនិយាយបាន។

ច្បាស់ណាស់ថា ការនេះមិនប្រើដើម្បីអនុវត្តសំរាប់យើងរាល់គ្នានៅពេលនេះនោះទេ ព្រះជាម្ចាស់មិនបានបញ្ឈប់យើងក្នុងការនិយាយស្តីឡើយ តែយើងត្រូវតែចែកឲ្យដាច់ថាពេលណា ដែលយើងត្រូវប្រកាសពីព្រះបន្ទូលរបស់ព្រះ ហើយពេលណា ដែលយើងគ្រាន់តែចែកចាយពីគំនិតយោបល់ផ្ទាល់ខ្លួនប៉ុណ្ណោះ។

សារដែលយើងបានឃើញនៅក្នុងជំពូក១-៣ នៃកណ្ឌគម្ពីរអេសេគាល នៅតែអាចប្រើក្នុងការអនុវត្តក្នុងសម័យកាលនេះ។ យើងនៅតែត្រូវការនិមិត្តពីភាពធំឧត្តមរបស់ព្រះជាម្ចាស់។ កណ្ឌគម្ពីរវិវរណៈ ដែលបានសរសេរឡើងសំរាប់គ្រីស្ទបរិស័ទគ្រប់គ្នា បានប្រើរូបភាពជាច្រើនចេញពីព្រះគម្ពីរអេសេគាល ដើម្បីពណ៌នាពីភាពធំឧត្តមរបស់ព្រះជាម្ចាស់ និងពីកូនចៀមរបស់ព្រះអង្គ។ យើងក៏ត្រូវបន្ទាបខ្លួននៅចំពោះសិរីល្អរបស់ព្រះគ្រីស្ទដូចគ្នាដែរ ដែលទ្រង់បានសុគត និងបានរស់ពីសុគតឡើងវិញក្នុងនាមជាអ្នកត្រួតត្រាលើគ្រប់ទាំងអស់ ហើយដែលទ្រង់មានព្រះជន្មរស់អស់កល្បជានិច្ច អាម៉ែន។

The above is an abridged translation of "The Call of a Prophet in Declining Times" by Don Carson. If you wish to hear the original English sermon, please go to http://thegospelcoalition.org/resources/a/Part-1-The-Call-of-a-Prophet-in-Declining-Times-Ezekiel-1-3